# ធម្មកថា

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ
## អំពីគោលបំណងនៃព្រះពុទ្ធដែលមិនឲ្យមនុស្សលោភ

**web site: hoksavann.org**

ថ្ងៃទី៧ តុលា ២០០៥

ពាក្យថាលោភចិត្តឬចិត្តលោភ ចេញមកពីបាលីថាលោភោ ប្រែថាសភាពធ្វើចិ
ត្តឲ្យជាប់ជំពាក់នៅក្នុងអារម្មណ៍ ។ លោភចិត្តនេះជាអកុសលមូលមួយក្នុងចំណោម
អកុសលមូលទាំងបីគឺ លោភៈ ទោសៈ និងមោហៈ ។ អកុសលមូលទាំងបីនេះជាឫ
សគល់នៃអកុសលទាំងពួង ។ រួចមកហើយមានអ្នកខ្លះយល់ច្រឡំថា បើព្រះពុទ្ធហា
មមិនឲ្យមនុស្សលោភ នោះនឹងធ្វើឲ្យអាក់ដំណើរលូតលាស់នៃសេដ្ឋកិច្ចជាតិ ។ ការ
យល់បែបនេះ មកអំពីគេពុំយល់ពាក្យថាលោភៈនេះ ។ ប្រហែលជាគេយល់ថា កុំឲ្យ
លោភបានន័យថា កុំឲ្យចង់បានច្រើន ពុំមែនមានន័យដូច្នេះឡើយ ។ មិនឲ្យលោភពុំ
មែនបានសេចក្ដីថា ហាមមិនឲ្យរៀនសូត្រ មិនឲ្យរកស៊ីធ្វើការចិញ្ចឹមជីវិតឡើយ សូ-
ម្បីព្រះសង្ឃព្រះពុទ្ធសាសនា ដែលលះបង់ស្ទើរទាំងអស់ហើយមកបួស ក៏លោក
ស្វែងរកបច្ច័យបួន ដើម្បីចិញ្ចឹមជីវិតដែរ ។ ដូច្នេះការរៀនសូត្រ ការធ្វើការងារចិញ្ចឹម
ប្រព្រឹត្តទៅធម្មតា ដែលព្រះពុទ្ធមិនត្រឹមតែពុំហាមទេ ថែមទាំងដាស់តឿនឲ្យខំប្រឹង
ប្រែងថែមទៀត ដូចជាពាក្យថា ឧបដ្ឋានសម្បទា ត្រូវខំប្រឹងប្រែងរៀនសូត្រ ធ្វើការ
ងារចិញ្ចឹមជីវិតឲ្យបានខ្លាំងក្លា តែត្រូវចៀសវាងការងារមិនប្រកបដោយធម៌គឺ ការ-
ងារទុច្ចរិតនិងអយុត្តិធម៌ ។ អារក្ខសម្បទា មានចំណេះវិជ្ជាហើយ បានទ្រព្យសម្បត្តិ
ហើយ ត្រូវរក្សាឲ្យគង់វង់ជាដើម ។ ធម៌នេះមាននិយាយក្នុងប្រយោជន៍បច្ចុប្បន្នបួន
យ៉ាង ។

ធម៌ដែលព្រះពុទ្ធមិនឲ្យលោភនេះ មានន័យដ៏ជ្រាលជ្រៅណាស់ ដែលជារូបម
ន្តរម្ងាប់សេចក្ដីទុក្ខផ្លូវចិត្តរបស់មនុស្ស ។ ពាក្យ វិគ្គហៈ ថា លុព្ភតីតិលោភោ កន្លែង
ខ្លះប្រែថាចង់បាន កន្លែងខ្លះប្រែថាការជាប់ចិត្ត ។ របស់អ្វីទាំងអស់ ទាំងមានវិញ្ញា-
ណ ទាំងឥតវិញ្ញាណ តែងតែស្ថិតនៅក្នុងភាពពុំទៀង តែងតែផ្លាស់ប្ដូរប្រែប្រួលហើ
យទីបំផុត ត្រូវវិនាស ត្រូវស្លាប់ទៅវិញ ។ បើចិត្តមនុស្សនៅតែជាប់ (លោភៈ) នូវ

របស់ដែលវិនាសហើយនោះ គេនឹងកើតទុក្ខផ្លូវចិត្តចំពោះសត្វ (របស់មានវិញ្ញាណ) និងសង្ខារ (របស់ឥតវិញ្ញាណ) ដែលវិនាសបាត់បង់ទៅហើយនោះ ។ ក្នុងទុក្ខ១២ កង មានទុក្ខមួយកងពោលថា សេចក្ដីទុក្ខកើតអំពីការបាត់បង់របស់ជាទីស្រឡាញ់របស់ខ្លួន (បិយេហិ វិប្បយោគោ ទុក្ខោ) ដូច្នេះបើចិត្តមិនជាប់ (អលោភៈ) សេចក្ដីទុកខ្ខផ្លូវចិត្តក៏ពុំមានដែរ ។ ក្នុងព្រះពុទ្ធសាសនាសំដែងឲ្យពិចារណាថា សង្ខារទាំងឡាយកើតមកហើយ តែងស្លាប់បាត់បង់ទៅវិញ មនុស្សសត្វទាំងឡាយ តែងតែព្រាត់ប្រាស់គ្នាជាធម្មតា ដូច្នេះការសោកស្ដាយ យំសោក ពុំអាចរស់ឡើងវិញឡើយ នាំតែខូចផ្លូវចិត្តប៉ុណ្ណោះ ។ គួរទាំងចិត្តជាឧបេក្ខា ពិចារណាកម្មផលរបស់មនុស្សសត្វបើពិចារណាក្នុងធម៌ករុណា ការអាណិតអាសូរចំពោះសត្វ និងសង្ខារដែលស្លាប់បាត់បង់ទៅ ដែលពុំរស់ឡើងវិញនោះ សេចក្ដីសោកស្ដាយតែងស្ថិតនៅក្នុងចិត្ត មានខ្លះសោកស្ដាយខ្លាំង រហូតធ្វើអត្តឃាត សម្លាប់ខ្លួនឯងក៏មាន ។ ការសោយសោកនោះមកអំពីចិត្តជាប់ (លោភៈ) មិនពិចារណាធ្វើការពិត ហើយលះបង់ចិត្តជាប់នេះ ។ បានសេចក្ដីថា បើម្ដាយឪពុក ជីដូនជីតា បងប្អូនកូនចៅ នៅរស់តោងតែគោរពគ្នាសង្គ្រោះគ្នា ស្រឡាញ់រាប់អានគ្នា ដល់ពេលស្លាប់បាត់បង់ព្រាត់ប្រាស់គ្នា ត្រូវប្រើទឹកចិត្តមួយផ្សេងពីនេះ ដោយពិចារណាកម្មផលរបស់មនុស្សសត្វ ប្រកដដោយឧបេក្ខាចិត្ត បើចិត្តផ្លាស់ប្ដូរមិនទាន់ ចិត្តរមែងកើតទុក្ខ ។ ចិត្តរបស់មនុស្សបថុជ្ជនផ្សេងពីចិត្តរបស់ព្រះអរិយបុគ្គល មានព្រះពុទ្ធជាដើម ។ ចិត្តព្រះអរិយបុគ្គលដែលជាព្រះអរហន្ត មានទស្សនៈឃើញការពិតថា រូបរាងកាយរបស់មនុស្សដែលប្រកបដោយខន្ធប្រាំគឺ រូបវេទនាសញ្ញា សង្ខារនិងវិញ្ញាណ ពុំមែនជាសត្វ ជាបុគ្គល មានសភាពសោះសូន្យទទេ ។ បានសេចក្ដីថា ខន្ធប្រាំគ្រាន់តែធាតុកើតឡើងតាំងនៅ និងរលត់ទៅវិញជាធម្មតា ជាអនត្តាបុំមានខ្លួន ជាសភាវធម៌ប្រព្រឹត្តទៅខ្លួនវា ពុំអាចបង្គាប់បញ្ជាបានឡើយ ដូច្នេះហើយបានជា ព្រះអរហន្តមានព្រះពុទ្ធជាដើម លោកពុំតក់ស្លុតភ័យខ្លាច សោកស្ដាយនូវជីវិត ទោះបីដល់នូវសេចក្ដីស្លាប់ក៏ដោយ ។ លោកចាត់ទុក្ខរូបរាងកាយ ជាធាតុបួនដូចធាតុខាងក្រៅ ។ ការមិនភ័យតក់ស្លុតនេះ ព្រោះលោកមិនជាប់ (អលោភៈ) ។ លោកនៅថែទាំរូបកាយនិងប្រើប្រាស់បច្ច័យបួន មានចីវបច្ច័យជាដើម ប៉ុន្តែបើរូបរាងកាយនិងវត្ថុទាំងនោះវិនាស ក៏លោកមានព្រះទ័យស្មើ មិនតក់ស្លុត មិនសោកស្ដាយសោះឡើយ ។ លោភ ការចង់បាន ឬការជាប់ជំពាក់ខ្លាំងអាចជំរុញចិត្តឲ្យលួចទ្រព្យសម្បត្តិអ្នកដទៃ និងជំរុញឲ្យធ្វើឃាតអ្នកដទៃដើម្បីបានទ្រព្យសម្បត្តិ ដូចជាចោរប្លន់សម្លាប់អ្នកម្ចាស់ទ្រព្យ ឬចាប់ជីវិតទារប្រាក់ជាដើម ។ បើអ្នករដ្ឋការវិញ ប្រព្រឹត្តអំពើពុករលួយដោយការលោភ ហួសព្រំដែនបាលីថា អភិជ្ឈាវិសមលោភ ប្រែជាការសម្លឹងរំពៃចង់បានទ្រព្យសម្បត្តិអ្នកដទៃនិងទ្រព្យសម្បត្តិជាតិ ។ ធម៌អកុសលគឺ លោភៈនេះហើយដែលធ្វើឲ្យប្រទេសក្នុងពិភពលោក មានចោរលួចចោរប្លន់ លួចរំកិលព្រំដែន កើតការវិវាទរវាងប្រទេសជិតខាងគ្នា ដូចប្រទេស

កម្ពុជាដែលកំពុងមានបញ្ហាទឹកដីជាមួយប្រទេសជិតខាងទាំងបីជាដើម ។ ការរំលោភសិទ្ធិប្រជាពលរដ្ឋរបស់អ្នកកាន់អំណាច ក៏មកអំពីការលោភលន់ហួសប្រមាណនេះឯង ។ សង្គ្រាមសកលលោកទាំងពីរលើក ក៏បណ្ដាលមកអំពីមហិច្ឆិតាលោភលន់ចង់ត្រួតត្រាលើសកលលោកដាច់មុខតែម្នាក់ឯង ។ លោភៈគ្របសង្កត់បិទបាំងមិនឲ្យបុគ្គលនឹកឃើញភាពពុំទៀង (អនិច្ចំ) នៃរូបរាងកាយឡើយ ។ គម្ពីរព្រះពុទ្ធសាសនាសំដែងថា កាលណាសន្ដានចិត្តនៃមនុស្សក្រាស់ដោយលោភៈ រមែងកើតទុរ-ភិក្សនិងអន្ដរាយផ្សេងៗដល់មនុស្សក្នុងបច្ចុប្បន្ន ហើយមនុស្សសត្វដែលទៅកើតជាប្រេតក៏មកអំពីលោភមូលចិត្តនេះឯង ។

ដូចបានពោលមកហើយ ព្រះពុទ្ធបានសំដែងក្នុងធម៌អភិធម្ម អំពីលោភចិត្តនេះវាជាឫសគល់នៃអកុសលទាំងឡាយ នាំសត្វឲ្យមានទុក្ខ ហើយឲ្យប្រព្រឹត្តអលោភចិត្ត គឺចិត្តមិនលោភជាឫសគល់នៃកុសលទាំងឡាយ នាំសត្វឲ្យបានសុខ ។ កាលណាចិត្តមិនលោភបានន័យថា មិនជាប់ទោះបីរបស់នោះវិនាសទៅក៏មិនកើតទុក្ខ នេះជាការដោះផ្លូវចិត្តយ៉ាងខ្ពស់បំផុត ដើម្បីចិត្តបរិសុទ្ធ បំណាងបំបាត់ទុក្ខ ព្រោះរបស់អ្វីទាំងអស់ដែលកើតឡើងពីគ្រឿងផ្សំ តែងតែវិនាសទៅវិញជាធម្មតា ។ អនិសង្សនៃការមិនលោភនាំឲ្យមនុស្សប្រកបកិច្ចការងារគ្រប់យ៉ាង ប្រកបដោយធម៌ (សម្មាអាជីវោ) មិនត្រឹមតែធ្វើខ្លួនអ្នកប្រព្រឹត្តឲ្យបានសុខទេ ថែមទាំងធ្វើឲ្យសង្គមបានសុខផងព្រោះពុំមានធម៌អទិន្នាទាន ការលួចប្លន់ ។ ការមិនលោភមិនត្រឹមតែពុំបង្អាក់ដំណើរការលូតលាស់សេដ្ឋកិច្ចគ្រួសារនិងសេដ្ឋកិច្ចជាតិទេ ថែមទាំងធ្វើឲ្យសេដ្ឋកិច្ចទាំងពីរនេះលូតលាស់ថែមទៀត ព្រោះមនុស្សដែលមានចិត្តមិនលោភ ជាមនុស្សមានចិត្តខ្ពស់ មានបញ្ញាដ៏ជ្រាលជ្រៅ ខំប្រឹងប្រែងធ្វើជីវិតខ្លួននិងជីវិតសង្គមឲ្យចំរើនលូតលាស់ ខាងសម្ភារៈ និងសីលធម៌ ប្រកបដោយធម៌ហើយរបស់ណាដែលបានមកឬកើតឡើងដោយធម៌ របស់នោះទុកគង់វង់ស្ថិតស្ថេរ ។៚